# សម្ពាធ ក្រោមម្ជើរ សាច់ក្រណាត់

## របាយការណ៍សង្ខេប

## ការបាត់បង់ប្រាក់ឈ្នួល នៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរកម្ពុជា




Clean Clothes Campaign

actionaid

# មាតិកា


០១ សនិទាន ........ ១

០២ របកគំហើញនៃការស្រាវជ្រាវ ........ ៣

- របកគំហើញទី១៖ ប្រាក់ឈ្នួលប្រចាំខែធ្លាក់ចុះ ........ ៤
- របកគំហើញទី២៖ ប្រព័ន្ធដែលពឹងផ្អែកលើការងារថែមម៉ោង........ ៥
- របកគំហើញទី៣៖ ការកើនឡើងនៃបំណុល ........ ៧
- អនុសាសន៍សំខាន់ៗ ........ ១០

០៣ សេចក្ដីសន្និដ្ឋាន ........ ១៦


សូមស្កេន QR Code ខាងក្រោម ដើម្បីទទួលបានរបាយការណ៍ពេញ៖

# ០១

# សន្និទាន

ក្រុមហ៊ុនម៉ាកសាកលជំពាក់ប្រាក់កម្មករកម្ពុជារាប់លានដុល្លារតាមរយៈការលួចប្រាក់ឈ្នួលនៅក្នុងអំឡុងពេលជំងឺកូវីដ១៩។ តាមការស្រាវជ្រាវ ដោយយុទ្ធនាការសម្អៀកបំពាក់ស្អាត (Clean Clothes Campaign) ដែលផ្សព្វផ្សាយក្នុងឆ្នាំ២០២១ និង ២០២២ បានប៉ាន់ប្រមាណ ទឹកប្រាក់ជំពាក់ កម្មករកម្ពុជា ទាំងប្រាក់ឈ្នួល និងប្រាក់បំណាច់បញ្ចប់កិច្ចសន្យា មានចំនួន **៣៩២.៩លាន ដុល្លារអាមេរិក** អំឡុងពេលព្យួរកិច្ចសន្យាការងារ និងបិទរោងចក្រ ចាប់ពី ខែកុម្ភៈ ឆ្នាំ២០២០ ដល់ ខែឧសភា ឆ្នាំ ២០២១។ ខាងក្រោមនេះជាទិន្នន័យ ប៉ាន់ប្រមាណប្រាក់ឈ្នួលដែលបាត់បង់នៅចន្លោះ ខែកុម្ភៈ ឆ្នាំ ២០២០ ដល់ ខែមេសា ឆ្នាំ ២០២១។

| ក្រុមហ៊ុនម៉ាក | ការប៉ាន់ប្រមាណនៃការលួចប្រាក់ឈ្នួល (គិតជាលានដុល្លារអាមេរិក) |
|---|---|
| **Adidas** | ១១,៧ |
| **Nike** | ៧,៥ |
| **Target USA** | ៧,៦ |
| **GAP** | ៦,៧ |
| **Puma** | ៥,៩ |
| **Levi Strauss** | ៣,៩ |

# ០២

# របកគំហើញនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើការអង្កេត និងប្រមូលទិន្នន័យជាមួយកម្មកររោងចក្រកាត់ដេរចំនួន ៣០៨ នាក់ ស្ត្រី ៦៥ភាគរយ ដែលត្រូវបានសម្ភាស ដោយអ្នកចងក្រងរបស់សហព័ន្ធសហជីពកម្ពុជា (CATU) និង សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU) ក្នុងកំឡុង ខែធ្នូ ឆ្នាំ២០២២ ដល់ ខែមករា ឆ្នាំ២០២៣។ ការសិក្សានេះក៏បានធ្វើការពិភាក្សាក្រុមជាមួយកម្មករដែលសម្ភាស និង តំណាងសហជីពដើម្បីផ្ទៀងផ្ទាត់របកគំហើញសំខាន់ៗនិង ពិគ្រោះយោបល់បន្ថែម សិក្សាលើឯកសារ ផ្សេងៗ ដូចជា បណ្ណបើកប្រាក់ឈ្នួលចេញដោយរោងចក្រ (factory-issued pay slips) ទិន្នន័យ បញ្ជូនទំនិញ និងទិន្នន័យនាំចេញ ព្រមទាំងឯកសារពាក់ព័ន្ធ និងឯកសារដែលមានស្រាប់មួយចំនួន ទៀត។ ការសិក្សាស្រាវជ្រាវ បានរកឃើញលទ្ធផលសំខាន់ៗចំនួនបីគឺៈ

1. ប្រាក់ឈ្នួលប្រចាំខែធ្លាក់ចុះ
2. ប្រព័ន្ធដែលពឹងផ្អែកលើការងារថែមម៉ោង
3. ការកើនឡើងនៃបំណុល

# របកគំហើញទី១៖ ប្រាក់ឈ្នួលប្រចាំខែធ្លាក់ចុះ

យ៉ាងហោចណាស់កម្មករសម្ភាស ២៥ភាគរយ រាយការណ៍ថាប្រាក់ឈ្នួលទទួលបានប្រចាំខែដោយមិនគិតបញ្ចូលប្រាក់ថៃមម៉ោងមានការថយចុះចាប់តាំងពីឆ្នាំ២០២០ ។ ថ្វីបើប្រាក់ឈ្នួលអប្បបរមាមានការកើនឡើងចំនួន ១០ដុល្លារអាមេរិក នៅក្នុងចន្លោះ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ កម្មករសម្ភាស ភាគច្រើន បានបញ្ជាក់ថា បច្ចុប្បន្នពួកគេទទួលប្រាក់ឈ្នួលបានតិចជាងកាលពីឆ្នាំ២០២០ មុនពេលវិបត្តិជំងឺកូវីដ១៩។

## របកគំហើញសំខាន់ៗ

- កម្មករសម្ភាស ២៥ភាគរយ រាយការណ៍អំពីការធ្លាក់ចុះនៃប្រាក់ឈ្នួលប្រចាំខែ ចាប់តាំងពីឆ្នាំ ២០២០។
- ៦៥ភាគរយ បានរាយការណ៍ថា ប្រាក់ឈ្នួលរបស់ពួកគេមិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ពួកគេរហូតដល់ចុងខែនោះឡើយ។
- កម្មករសម្ភាសទាំងអស់ រកប្រាក់ឈ្នួលបានក្រោម ៧០១ ដុល្លារអាមេរិក ជាប្រាក់ឈ្នួលដែលអាចរស់នៅបាន យោងតាមការប៉ាន់ប្រមាណដោយ AFWA។
- ការបាត់បង់ប្រាក់ឈ្នួលជាប្រព័ន្ធនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាទាំងមូល គឺកើតឡើងដោយសារថ្លៃចំណាយសម្រាប់ការរស់នៅកាន់តែឡើងថ្លៃ។
- ប្រាក់ឈ្នួលអប្បបរមារបស់កម្មករចំនួន ២០០ដុល្លារអាមេរិក គឺបានត្រឹមតែ ២៨,៥ភាគរយ នៃប្រាក់ឈ្នួលដែលអាចរស់បានគឺបង្ហាញពីបញ្ហារ៉ាំរ៉ៃនៃប្រាក់ឈ្នួលអប្បបរមាដែលមិនអាចឆ្លើយតបជាមួយនឹងអតិផរណា និងធ្វើអោយកម្មករធ្លាក់ក្នុងភាពក្រីក្រកាន់តែខ្លាំង។

នៅក្នុងប្រទេសកម្ពុជា គម្លាតរវាងប្រាក់ឈ្នួលអប្បបរមា និងប្រាក់ឈ្នួលដែលអាចរស់បានគឺកាន់តែធំ។ ប្រាក់ឈ្នួលអប្បបរមា គឺបានត្រឹម ២៨,៥ភាគរយ នៃប្រាក់ឈ្នួលដែលអាចរស់បានប៉ុណ្ណោះ មានន័យថា កម្មករកាត់ដេរ ដែលជួយរកប្រាក់ចំណូលរាប់សិបកោដដុល្លារអាមេរិកសម្រាប់ក្រុមហ៊ុនម៉ាកសម្លៀកបំពាក់ធំៗ ទទួលប្រាក់ឈ្នួលមិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេឡើយ។

*"ប្រាក់ឈ្នួលអប្បបរមា គឺ ២០០ដុល្លារអាមេរិក ប៉ុន្តែ.... ពួកគេត្រូវដេរឲ្យគ្រប់ចំនួនកំណត់ ដើម្បីទទួលបានប្រាក់ឈ្នួលអប្បបរមា។ កាលពីមុន ប្រសិនបើពួកគេដេរលើសចំនួនកំណត់ក្នុងម៉ោងការងារធម្មតា ពួកគេនឹងទទួលបានប្រាក់ឈ្នួលខ្ពស់ ហើយប្រសិនបើពួកគេធ្វើការងារថែមម៉ោង ពួកគេនឹងទទួលបានប្រាក់បន្ថែមពីលើនោះទៀត។ ប៉ុន្តែបច្ចុប្បន្ន ដោយសារគ្មានការងារគ្រប់គ្រាន់ ពួកគេទទួលបានត្រឹមតែប្រាក់ឈ្នួលអប្បបរមាប៉ុណ្ណោះ... ពួកគេមិនបានទទួលប្រាក់រង្វាន់ដេរលើសចំនួនកំណត់ព្រោះមិនមានការងារគ្រប់គ្រាន់ឱ្យធ្វើទេ។"*

**– សម្រង់សម្ដីថ្នាក់ដឹកនាំសហជីពឯករាជ្យ**

# របកគំហើញទី២៖

# ប្រព័ន្ធដែលពឹងផ្អែកលើការងារថែមម៉ោង

សម្រាប់កម្មករសម្ភាស ប្រាក់ថែមម៉ោងមានការថយចុះជាង ៦០ភាគរយ ក្នុងចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។ កម្មករដែលធ្លាប់រកប្រាក់បានជាមធ្យម ៣៦ដុល្លារអាមេរិក តាមរយៈការងារថែមម៉ោងមុនពេលជំងឺកូវីដ១៩ គឺអាចរកប្រាក់បាន ត្រឹមតែ ១២ដុល្លារអាមេរិក ក្នុងមួយខែ ក្នុងឆ្នាំ២០២៣ ។ នៅក្នុងប្រទេសមួយដែលកម្មករកាត់ដេរត្រូវពឹងផ្អែកលើការងារថែមម៉ោងដើម្បីបំពេញបន្ថែមលើប្រាក់ឈ្នួលអប្បបរមារបស់ខ្លួន កម្មករគឺចាំបាច់ត្រូវកាត់បន្ថយបរិមាណអាហារបរិភោគប្រចាំថ្ងៃ និងថ្លៃចំណាយសម្រាប់ការអប់រំកូនៗរបស់ខ្លួន។

## របកគំហើញសំខាន់ៗ

- ប្រាក់ថៃមម៉ោងរបស់កម្មករសម្អាសបានថយចុះជាង ៦០ភាគរយ ពួកគេទទួលបាន ជាមធ្យមប្រមាណ ៣៦ដុល្លារអាមេរិក នៅមុនពេលមានជំងឺកូវីដ១៩ ដែលបច្ចុប្បន្នគឺបានជាមធ្យម ១២ដុល្លារអាមេរិក ក្នុងមួយខែ ។
- មានកម្មករចំនួន ៤ភាគរយ ប៉ុណ្ណោះដែលមានការងារថៃមម៉ោងគ្រប់គ្រាន់ សម្រាប់អ្នកដែលចង់ធ្វើការងារថៃមម៉ោង។
- កម្មករលើកឡើងថាមានការថយចុះការងារថៃមម៉ោង គឺបណ្តាលមកពីការថយចុះការបញ្ជាទិញពីក្រុមហ៊ុនម៉ាក និងសម្ពាធពីថៅកែរោងចក្រ ដែលតម្រូវឱ្យកម្មករដេរចំនួនកំណត់ខ្ពស់នៅក្នុងម៉ោងការងារធម្មតា។

កម្មករសម្អាស ភាគច្រើនបានរាយការណ៍ថា ពួកគេធ្វើការថៃមម៉ោងច្រើន មុនពេលកើតមានជំងឺកូវីដ១៩ និងមានកម្មករប្រមាណ ២១ភាគរយ ប៉ុណ្ណោះដែលមិនធ្វើការងារថៃមម៉ោង។ ប្រាក់ថៃមម៉ោងដែលកម្មករទទួលបានជាមធ្យម ៣៦ដុល្លារអាមេរិក ដែលស្មើនឹង ២០ភាគរយនៃប្រាក់ឈ្នួលអប្បរមា ១៩០ដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។ ផ្ទុយទៅវិញ កម្មករសម្អាស ៦៧ភាគរយ រាយការណ៍ថាបច្ចុប្បន្នពួកគេមិនបានធ្វើការងារថៃមម៉ោងទេ។ សម្រាប់កម្មករធ្វើការងារថៃមម៉ោងទទួលប្រាក់ជាមធ្យម ១២ដុល្លារអាមេរិក ក្នុងមួយខែ។ ប្រាក់ថៃមម៉ោងបានធ្លាក់ចុះជាង ៦០ភាគរយ បើប្រៀបធៀបមុនពេលមានការរីករាលដាលនៃជំងឺកូវីដ១៩។

# របកគំហើញទី៣៖ ការកើនឡើងនៃបំណុល

កម្មករសម្ភាស ៩១ភាគរយ រាយការណ៍ថា ពួកគេជំពាក់បំណុលយ៉ាងហោចណាស់ចំនួនមួយនៅពេលបច្ចុប្បន្ន និង ៧០ភាគរយ លើកឡើងថា ការរាតត្បាតនៃជំងឺកូវីដ១៩ គឺជាមូលហេតុមួយដែលធ្វើឱ្យបំណុលកើនឡើង។ នៅពេលថ្លៃចំណាយរស់នៅកើនឡើង កម្មករបានទៅរកប្រាក់កម្ចីដែលមានអត្រាការប្រាក់ខ្ពស់រហូតដល់២០ភាគរយ ហើយកម្មករមួយចំនួនបានបញ្ជាក់ពីនិន្នាការថ្មីមួយដែលគួរឱ្យព្រួយបារម្ភ គឺការខ្ចីប្រាក់ពីប្រធានក្រុមនៅក្នុងរោងចក្រ។

## របកគំហើញសំខាន់ៗ

- ជិតពាក់កណ្តាលនៃកម្មករសម្ភាស ដែលមាន ៤៩ភាគរយ រាយការណ៍ថាពួកគេតែងទៅធ្វើការដោយពុំបានហូបអាហារគ្រប់គ្រាន់។
- កម្មករ ៩១ភាគរយ ជំពាក់បំណុល ហើយ ៧០ភាគរយ បញ្ជាក់ថាបំណុលរបស់ពួកគេមានការកើនឡើងចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ១៩។
- កម្មករជិត ៤០ភាគរយ ដែលជំពាក់បំណុលរាយការណ៍ថា ពួកគេជំពាក់បំណុលច្រើនជាងមួយ ដោយក្នុងនោះកម្មករជិត ១០ភាគរយ ត្រូវសងបំណុលចំនួន ៣ ម្ចាស់បំណុល ឬច្រើនជាងនេះ។
- កម្មករដែលមានបំណុលប្រមាណ ៥៤ភាគរយ រាយការណ៍ថា ជារឿយៗ ពួកគេពុំអាចសងបំណុលរបស់ខ្លួនបានឡើយ។
- ក្នុងពេលវិបត្តិថ្លៃចំណាយកើនឡើង កម្មករជាច្រើនងាកទៅរកកម្ចីក្រៅប្រព័ន្ធដែលមានអត្រាការប្រាក់ខ្ពស់រហូតដល់ ២០ភាគរយ ដែលធ្វើឱ្យមានវិបត្តិបំណុលគ្រួសារកាន់តែខ្លាំងឡើងគ្មានទីបញ្ចប់។

ការស្រាវជ្រាវនេះ បង្ហាញឱ្យឃើញថា នៅពេលកម្មករខ្វះខាតហិរញ្ញវត្ថុកាន់តែខ្លាំង បំណុលគ្រួសារកើតមានកាន់តែច្រើន។ កម្មករសម្ភាស ៩១ភាគរយ រាយការណ៍ថាពួកគេមានបំណុល ហើយមានតែ ៨ ភាគរយ ប៉ុណ្ណោះដែលមិនមានបំណុល។ កម្មករសម្ភាស ៧០ភាគរយ បញ្ជាក់ថា បំណុលរបស់ពួកគេបានកើនឡើងចាប់តាំងពីកើតមានការរាតត្បាតនៃជំងឺកូវីដ១៩។ បញ្ហានេះកើតឡើង គឺដោយសាររោងចក្រជាច្រើនព្យួរកិច្ចសន្យាការងារក្នុងអំឡុងពេលបិទខ្ទប់ដោយជំងឺកូវីដ១៩ ដែលធ្វើឱ្យប្រាក់ឈ្នួល និងការងារថែមម៉ោងត្រូវបានធ្លាក់ចុះចាប់ពីឆ្នាំ២០២០មក ហើយថ្លៃចំណាយសម្រាប់ការរស់កើនឡើងខ្ពស់។

*"គ្រប់គ្នាសុទ្ធតែមានបំណុល ហើយគិតច្រើនអំពីបំណុលទាំងនោះ។ យើងពិបាកចិត្ត គិតច្រើន មិនដឹងថាបានលុយពីណាទៅសងការប្រាក់គេ ដូច្នេះ គឺយើងមិនអាចផ្ដោតអារម្មណ៍ធ្វើការបានពេញលេញទេ។ យើងគិតរកវិធីកាត់បន្ថយថ្លៃចំណាយដើម្បីយកលុយទៅសងបំណុល ដូចជាត្រូវកាត់បន្ថយថ្លៃកូនរៀន ថ្លៃអាហារជាដើម។ ប៉ុន្តែបើយើងហូបមិនបានគ្រប់គ្រាន់ យើងក៏មិនអាចផ្ដោតលើការងារបានដែរ។"*

– **កម្មករនៅរោងចក្រ Berry Apparel**

ក្នុងចំណោមកម្មករសម្ភាស ៩៨នាក់ ដែលកំពុងមានបំណុល ៤៦ភាគរយ បានរាយការណ៍ថា បំណុលរបស់ពួកគេគឺចាប់ពី ១០០០ដុល្លារអាមេរិក រហូតដល់ ៨០០០ដុល្លារអាមេរិក ៤៧ភាគរយ មានបំណុលយ៉ាងហោចណាស់ ១០.០០០ដុល្លារអាមេរិក និងកម្មករមួយចំនួនមានបំណុលរហូតដល់ ៣៥.០០០ ដុល្លារអាមេរិក។ ចំណុចដែលព្រួយបារម្ភគឺ ចំនួនកម្មករកាន់តែច្រើនមានបំណុលច្រើនជាង ១បំណុល ដែលធ្វើឱ្យកម្មករនៅក្នុងឧស្សាហកម្មនេះទាំងមូលមិនមានសុវត្ថិភាព។ ក្នុងចំណោមកម្មករ ២៨១នាក់ ដែលរាយការណ៍ថាមានបំណុល ៣០ភាគរយ មានបំណុលចំនួន ២បំណុល ហើយ ៧ភាគរយ មានបំណុល ៣ ឬច្រើនជាងនេះ។ នេះមានន័យថា កម្មករសម្ភាសដែលមានបំណុលប្រមាណ ៤០ ភាគរយ កំពុងតែត្រូវសងបំណុលខណៈដែលប្រាក់ឈ្នួលកាន់តែតិច ហើយអតិផរណា និងថ្លៃចំណាយកើនឡើងកាន់តែខ្ពស់។ មានច្រើនករណីដែលកម្មករត្រូវខ្ចីបំណុលថ្មីដើម្បីយកទៅសងបំណុលចាស់ ជាហេតុនាំឱ្យមានបន្ទុកបំណុលកាន់តែកើនឡើងជាលំដាប់។ បញ្ហានេះកាន់តែរីកធំឡើងទ្វេគុណនៅពេលប្រាក់ឈ្នួលរបស់កម្មករបានត្រឹមតែសងការប្រាក់ និងមិនអាចបង់សងថ្លៃដើមបាន។

| បំណុលនៅក្នុងឧស្សាហកម្មកាត់ដេរ | | | |
|---|---|---|---|
| ឈ្មោះរោងចក្រ | ភាគរយកម្មករសម្ភាសដែលមានបំណុល | ចំនួនកម្ចី | ភាគរយកម្មករសម្ភាសដែលមានភាពលំបាកក្នុងការសងប្រាក់កម្ចី |
| Apple Apparel* | ៩៨ភាគរយ | កម្ចីចំនួន ១ មាន ៨៨ភាគរយ | ២១ភាគរយ |
| Berry Apparel | ៩១ភាគរយ | កម្ចីចំនួន ១ មាន ៨៧ភាគរយ<br>កម្ចីចំនួន ២ ទៅ ៣ មាន ១៣ភាគរយ | ២៣ភាគរយ |
| Can Sports Shoes | ៩៦ភាគរយ | កម្ចីចំនួន ១ មាន ២៨ភាគរយ<br>កម្ចីចំនួន ២ ទៅ ៣ មាន ៥៦ភាគរយ<br>កម្ចីចំនួន ៤ ទៅ ៥ មាន ១៦ភាគរយ | ៨០ភាគរយ |
| Meng Da Footwear* | ៧៨ភាគរយ | កម្ចីចំនួន ១ មាន ៨២,៥ភាគរយ<br>កម្ចីចំនួន ២ ទៅ ៣ មាន ១៥ភាគរយ | ៥០ភាគរយ |
| Trax Apparel | ៨៨ភាគរយ | កម្ចីចំនួន ១ មាន ៦៧ភាគរយ<br>កម្ចីចំនួន ២ មាន ៣៣ភាគរយ | ៦០ភាគរយ |
| Yi Da Manufacturer | ៩៨ភាគរយ | កម្ចីចំនួន ១ មាន ១៦,5ភាគរយ<br>កម្ចីចំនួន ២ ទៅ ៣ មាន ៧៨ភាគរយ<br>កម្ចីចំនួន ៤ ទៅ ៥ មាន ៥,៥ភាគរយ | ៨៧ភាគរយ |

** ចំនួនកម្ចីបូកបញ្ចូលគ្នា ពុំស្មើនឹង ១០០ភាគរយទេ បណ្តាលមកពីមានអ្នកមិនបានផ្តល់ចម្លើយ*

# អនុសាសន៍សំខាន់ៗ

## អនុសាសន៍សំខាន់ៗសម្រាប់ក្រុមហ៊ុនម៉ាកក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងស្បែកជើង៖

- បោះពុម្ពផ្សព្វផ្សាយ និងរក្សាបញ្ជីឈ្មោះរោងចក្រផ្គត់ផ្គង់គ្រប់កម្រិតទាំងអស់នៃសង្វាក់ផ្គត់ផ្គង់ រួមទាំងរោងចក្រម៉ៅការបន្តផងដែរ។
- ដោះស្រាយវិវាទស្តីពីការលួចប្រាក់ឈ្នួល និងប្រាក់បំណាច់ក្នុងសង្វាក់ផ្គត់ផ្គង់ជាបន្ទាន់ ដើម្បីឱ្យកម្មករកាត់ដេរទទួលបានប្រាក់ឈ្នួល ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា និងអត្ថប្រយោជន៍ផ្សេងៗតាមច្បាប់។
- ប្តេជ្ញាចិត្តជាសាធារណៈក្នុងការអភិវឌ្ឍគោលនយោបាយ និងនីតិវិធីដើម្បីផ្តល់ប្រាក់ឈ្នួលដែលអាចរស់នៅបានសម្រាប់កម្មករទាំងអស់នៅក្នុងសង្វាក់ផ្គត់ផ្គង់ ព្រមទាំងចេញផ្សាយផែនការលម្អិតដែលបញ្ជាក់អំពីក្របខ័ណ្ឌពេលវេលា និងជំហានដែលត្រូវធ្វើ ដើម្បីធានាឱ្យបានថា រោងចក្រទាំងអស់ដែលខ្លួនធ្វើការជាមួយ ផ្តល់ប្រាក់ឈ្នួលដែលអាចរស់នៅបានដល់កម្មករ។
- បោះពុម្ពផ្សាយ និងជំរុញការអនុវត្តគោលនយោបាយប្រតិបត្តិការទិញដោយទទួលខុសត្រូវដែលអនុលោមតាមកាតព្វកិច្ចរបស់ក្រុមហ៊ុនម៉ាកក្រោមគោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ព្រមទាំងគោលការណ៍ណែនាំការត្រួតពិនិត្យភាពត្រឹមត្រូវតាមនីតិវិធីរបស់ OECD សម្រាប់សង្វាក់ផ្គត់ផ្គង់ប្រកបដោយការទទួលខុសត្រូវក្នុងវិស័យកាត់ដេរ និងស្បែកជើង។
- ការប្រតិបត្តិក្នុងការទិញរបស់ក្រុមហ៊ុនម៉ាក គួរផ្តល់ស្ថិរភាពការបញ្ជាទិញដល់រោងចក្រផ្គត់ផ្គង់ ព្រមទាំងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើផែនការ និងការអនុវត្តតាមការបញ្ជាទិញ។ គួរទូទាត់ប្រាក់ឱ្យទាន់ពេលវេលា ហើយគំរូការចំណាយដែលក្រុមហ៊ុនប្រើប្រាស់ គួរអនុញ្ញាតឱ្យអាចបង់ប្រាក់ឈ្នួលរស់នៅបាន និងអត្ថប្រយោជន៍ ព្រមទាំងផ្តល់កិច្ចគាំពារសង្គម និងអនុវត្តកិច្ចការពារសុវត្ថិភាពកម្មករ។

# អនុសាសន៍សំខាន់ៗសម្រាប់រាជរដ្ឋាភិបាលកម្ពុជា៖

- ដំឡើងប្រាក់ឈ្នួលអប្បបរមាដើម្បីធានាឱ្យបានថាប្រាក់ឈ្នួលសម្រាប់ឧស្សាហកម្មកាត់ដេរគឺគ្រប់គ្រាន់សម្រាប់ការចំណាយលើតម្រូវការមូលដ្ឋានដូចជាអាហារ លំនៅឋាន និង ការផ្គត់ផ្គង់ ការអប់រំ សម្ភារបរិក្ខារប្រើប្រាស់ផ្សេងៗទៀត។
- ពិចារណាពិនិត្យមើលជាថ្មីនៃច្បាប់ស្តីពីការងារដើម្បីឆ្លើយតបចំពោះការអនុវត្តរបស់រោងចក្រដែលកាត់បន្ថយម៉ោងការងារ និងធានាការអនុវត្តប្រាក់ឈ្នួលអប្បបរមានៅក្នុងរោងចក្រ ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពង្រឹងការអនុវត្តយន្តការនានាដូចជា អធិការកិច្ចការងារជាដើម ដើម្បីធានាឱ្យបានថា រោងចក្រមិនប្រើប្រាស់ការកំណត់ចំនួនផលិតដើម្បីបង់ប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមាដល់កម្មករ។
- ធនាគារជាតិកម្ពុជាគួរពិចារណាពិនិត្យឡើងវិញ និងធ្វើនិយ័តកម្មលើអត្រាការប្រាក់សម្រាប់មីក្រូហិរញ្ញវត្ថុ ធនាគារ និងអ្នកចងការប្រាក់ក្រៅប្រព័ន្ធស្របតាមបទដ្ឋានអន្តរជាតិ។
- ពិចារណាអនុវត្តគោលនយោបាយគ្រប់គ្រងថ្លៃឈ្នួលកន្លែងស្នាក់នៅសម្រាប់កម្មករកាត់ដេរដើម្បីដោះស្រាយចំពោះការឡើងថ្លៃ។

## អនុសាសន៍សំខាន់ៗសម្រាប់រដ្ឋាភិបាលអូស្ត្រាលី សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក៖

- សហភាពអឺរ៉ុប និងរដ្ឋដែលជាសមាជិកគួរតែបង្កើត និងអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកនិរន្តរភាពផ្នែកសាជីវកម្ម។ លិខិតបទដ្ឋានគតិយុត្តនេះ គួរតម្រូវថា ក្នុងបរិបទកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន ក្រុមហ៊ុនត្រូវកែសម្រួលការប្រតិបត្តិអាជីវកម្ម និងការប្រតិបត្តិក្នុងការទិញ ព្រមទាំងធានាយ៉ាងណាឱ្យកម្មករស្ថិតក្នុងសង្វាក់ផ្គត់ផ្គង់ បានទទួលប្រាក់ឈ្នួលដែលអាចរស់នៅបាន។
- សហភាពអឺរ៉ុបគួរបង្កើតឱ្យមានលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែក ដើម្បីហាមឃាត់ការប្រើប្រាស់ការប្រតិបត្តិពាណិជ្ជកម្មអយុត្តិធម៌នៅក្នុងវិស័យវាយនភណ្ឌកាត់ដេរ សម្លៀកបំពាក់។ ការអនុវត្តដូចជា តម្លៃក្រោមថ្លៃចំណាយផលិតកម្ម ការបង់ប្រាក់យឺតយ៉ាវ ឬការលុបចោលការបញ្ជាទិញប្រញាប់ប្រញាល់ នឹងត្រូវចាត់ទុកជាទង្វើខុសច្បាប់។
- សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក គួររក្សាសេចក្តីសម្រេចលើការអនុគ្រោះពាណិជ្ជកម្មជាមួយប្រទេសកម្ពុជារហូតមានការកែលម្អជាក់ស្តែង និងប្រកបដោយនិរន្តរភាពចំពោះសិទ្ធិមនុស្ស និងសិទ្ធិការងារនៅក្នុងប្រទេសកម្ពុជា។
- ប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក គួរពិចារណាយកសហភាពអឺរ៉ុបជាគំរូទាក់ទងជាមួយមគ្គទេសក៍ដើម្បីបង្កើតលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួន ដើម្បីធានាឱ្យមានការទទួលខុសត្រូវលើសង្វាក់ផ្គត់ផ្គង់។ ប្រទេសទាំងពីរ គួរដាក់ឱ្យមានលិខិតបទដ្ឋានគតិយុត្តដែលកំណត់កាតព្វកិច្ចឱ្យក្រុមហ៊ុនដែលកំពុងមានប្រតិបត្តិការនៅក្រៅប្រទេសត្រូវអនុវត្តគោលការណ៍សិទ្ធិមនុស្សដែលឆ្លើយតបនឹងយេនឌ័រ។ លិខិតបទដ្ឋានគតិយុត្តនេះគួរបង្កើតឱ្យមានយន្តការដោះស្រាយឯករាជ្យ មានធនធានគ្រប់គ្រាន់ មានគណនេយ្យភាព និងតម្លាភាពដែលងាយស្រួលក្នុងការអនុវត្ត ហើយមានយុត្តាធិការក្នុងការស៊ើបអង្កេត ព្រមទាំងផ្តល់សំណង និងជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព។
- ប្រទេសអូស្ត្រាលីគួរតែមានកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងសមភាពយេនឌ័រ។ ការអនុវត្តបទប្បញ្ញត្តិកាតព្វកិច្ចសិទ្ធិការងារ គួរត្រូវបានរួមបញ្ចូលនៅក្នុងគ្រប់កិច្ចព្រមព្រៀងទាំងអស់ ហើយបទប្បញ្ញត្តិទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិកម្មករ មិនថាប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលក្នុងប្រទេសអូស្ត្រាលី ឬក្នុងបណ្តាប្រទេសដៃគូក្តី គឺត្រូវដកចេញ។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម គួររួមមានយន្តការដោះស្រាយដែលអនុញ្ញាតឱ្យកម្មករអាចទទួលបានសំណងឆ្លើយតបនឹងករណីរំលោភបំពានសិទ្ធិមនុស្ស។

# ករណីសិក្សា៖ ករណីប្រាក់បំណាច់បញ្ចប់កិច្ចសន្យានៅរោងចក្រ Violet Apparel

ក្នុងខែឧសភា ឆ្នាំ២០២០ រោងចក្រវ៉ាយអូលែត (VIOLET APPAREL CAMBODIA CO,.LTD.) ដែលផលិតសម្រាប់ក្រុមហ៊ុនម៉ាកអន្តរជាតិ រួមមានដូចជា Nike និង Matalan ជាដើម បានផ្អាកប្រតិបត្តិការទាំងអស់ជាកិច្ចឆ្លើយតបចំពោះវិបត្តិជំងឺកូវីដ១៩។ នៅពេលរោងចក្រត្រូវបិទទ្វារភ្លាមៗ នៅថ្ងៃទី១ ខែកក្កដា នាពេលនោះកម្មករកាត់ដេរចំនួន ១២៨៤នាក់ ត្រូវបានបញ្ឈប់ពីការងារដោយមានការជូនដំណឹងត្រឹមតែ ២៤ម៉ោង ប៉ុណ្ណោះ។

រោងចក្របដិសេធមិនព្រមបង់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ប្រាក់ជំនួសការឈប់សម្រាក និងថ្ងៃបុណ្យដែលជាសិទ្ធិមានចែងក្នុងច្បាប់ស្តីពីការងារនៅកម្ពុជាទៅឱ្យកម្មករទាំងនោះទេ។ ថ្វីបើកម្មករមួយចំនួនបានទទួលដំណោះស្រាយ ប៉ុន្តែកម្មករជាច្រើនអះអាងថា ការដោះស្រាយគឺទាបជាងអ្វីដែលជំពាក់ពួកគេ។ ជាសរុប ប្រាក់សំណងដែលនៅជំពាក់កម្មករទាំងអស់ គឺមានទឹកប្រាក់ **១,៤ លានដុល្លារអាមេរិក**។

*"យើងទទួលបានប្រាក់ ៤០ដុល្លារអាមេរិក ក្នុងមួយខែក្នុងពេលព្យួរការងារ ប៉ុន្តែនៅពេលនោះ រោងចក្រក៏បិទទ្វារ ហើយយើងក៏មិនបានទទួលអ្វីទាំងអស់។ ពួកគេធ្វើឱ្យយើងសប្បាយចិត្តនៅពេលដំបូងដោយពួកគេនិយាយថា រោងចក្រនឹងត្រូវបិទទ្វារ ហើយយើងទទួលបានសំណងទៅតាមច្បាប់ក្នុងស្រុក ប៉ុន្តែការពិតពុំបានដូចគេនិយាយទេ។"*

នៅពេលរោងចក្របដិសេធមិនព្រមបង់អ្វីដែលរោងចក្រជំពាក់កម្មករធ្វើឱ្យកម្មករជាច្រើនធ្វើកូដកម្ម។ ដោយមានការគាំទ្រពីសហព័ន្ធសហជីពកម្ពុជា (CATU) នៅពេលនោះកម្មករបានលើកវិវាទការងាររួមទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយទាមទារឱ្យម្ចាស់រោងចក្រគឺ Ramatex Group ដែលមានជនជាតិសិង្ហបុរី និងម៉ាឡេស៊ីជាម្ចាស់ ត្រូវសងសំណងដែលនៅសល់ឱ្យពួកគេវិញ។

សំណុំរឿងនេះត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា ដែលជាស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្តោតលើវិស័យការងារតែមួយគត់នៅក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងនេះក្តី ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធមិនពិចារណាលើសំណុំរឿងនេះទេ ដោយលើកឡើងថា វិវាទនេះមិនស្ថិតក្រោមយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ អង្គការសិទ្ធិមនុស្សអន្តរជាតិ រួមមានអង្គការ **Human Rights Watch** និង **Worker Rights Consortium**[i] បានជំទាស់នឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយសមាគមឧស្សាហកម្មក៏បានលើកពីកង្វល់អំពីសិទ្ធិការងារនៅក្នុងវិស័យកាត់ដេរកម្ពុជាផងដែរ។

*“ពេលរោងចក្របិទទ្វារ គេបានបញ្ជូនអ្នកតំណាងក្រសួង... គេបានគណនាប្រាក់សំណងមិនត្រឹមត្រូវ។ គេស្តាប់តែកង្វល់របស់រោងចក្រ តែគេមិនស្តាប់ផលប្រយោជន៍របស់កម្មករទេ... គេមិនទាំងអនុញ្ញាតឱ្យយើងដឹងអំពីរឿងនេះផង។”*

ផ្អែកលើការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមហ៊ុន **Ramatex Group** ដែលជាក្រុមហ៊ុនវាយនភណ្ឌកាត់ដេរមានតម្លៃរាប់លានដុល្លារ មានរោងចក្រប្រមាណ ២០ ក្នុងតំបន់អាស៊ី បានបដិសេធមិនព្រមផ្តល់សំណងបន្ថែមទៀតដល់កម្មកររោងចក្រ **Violet Apparel**។ ក្រុមហ៊ុន **Nike** ក៏បានបដិសេធមិនទទួលលខុសត្រូវចំពោះសំណុំរឿងនេះ ដោយអះអាងថា ខ្លួនបានបញ្ចប់ទំនាក់ទំនងជាមួយរោងចក្រក្នុងឆ្នាំ ២០០៦ បើទោះបីជាមានភស្តុតាងយ៉ាងរឹងមាំបង្ហាញថា រោងចក្រនៅតែផលិតសម្លៀកបំពាក់ឱ្យក្រុមហ៊ុន **Nike** ជារោងចក្រម៉ៅការបន្តអស់ពេលជាច្រើនឆ្នាំក្តី។ ក្រុមហ៊ុន **Nike** ក៏មិនបានប្រើប្រាស់ភាពជាដៃគូអាជីវកម្មរយៈពេលវែងរបស់ខ្លួនជាមួយក្រុមហ៊ុន **Ramatex Group** ដើម្បីស្វែងរកដំណោះស្រាយសម្រាប់សំណុំរឿងនេះឡើយ។[i] [i]

# ការគ្មានការងារធ្វើបានរីករាលដាល

បីឆ្នាំក្រោយរោងចក្រ Violet Apparel បិទទ្វារ ជីវិតកម្មករកាត់ដេរនៅក្នុងសំណុំរឿងនេះ បានធ្លាក់ដុនដាបកាន់តែយ៉ាប់យ៉ឺនទៅៗ។ អតីតកម្មកររោងចក្រ Violet Apparel ចំនួន ២៦នាក់ បានចូលរួមក្នុងការសិក្សានេះ ប្រមាណមួយភាគបីបានរាយការណ៍ថា ពួកគេលែងមានចំណូលទៀងទាត់ មួយចំនួនគ្មានការងារធ្វើ និងមួយចំនួនទៀតធ្វើការទទួលបានប្រាក់ឈ្នួលតាមម៉ោង ឬទទួលបានប្រាក់ឈ្នួលគិតជាថ្ងៃនៅពេលមានការងារធ្វើ។ ក្នុងករណីខ្លះ កម្មករបានរាយការណ៍ថា សកម្មភាពដែលសហជីពរបស់ពួកគេឆ្លើយតបនឹងការបិទទ្វាររោងចក្រ Violet Apparel បានធ្វើឱ្យពួកគេស្ថិតក្នុងបញ្ជីខ្មៅរបស់រោងចក្រដទៃទៀតដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន Ramatex ឬក្នុងឧស្សាហកម្មកាត់ដេរទាំងមូលតែម្តង។

*“ខ្ញុំជួបការលំបាកច្រើនណាស់ ហើយខ្ញុំនៅតែមិនទាន់មានការងារធ្វើនៅឡើយ។ សម្រាប់ថ្នាក់ដឹកនាំសហជីពគឺមានការលំបាកណាស់ ព្រោះកន្លែងជាច្រើនរើសអើងបដិសេធមិនទទួលយកខ្ញុំធ្វើការទេ។ នៅពេលយើងដាក់ពាក្យរកការងារធ្វើ យើងចាំបាច់ត្រូវផ្តល់អត្តសញ្ញាណបណ្ណរបស់យើងឱ្យគេ ហើយអត្តសញ្ញាណបណ្ណរបស់ខ្ញុំត្រូវបានគេដាក់ក្នុងបញ្ជីខ្មៅ។”*

បន្ថែមពីនេះទៀត កម្មកររោងចក្រ Violet Apparel ដែលបានសម្ភាស ១៩ភាគរយ បានរាយការណ៍ថា ពួកគេរកប្រាក់បានក្រោមប្រាក់ឈ្នួលអប្បបរមា ២០០ ដុល្លារអាមេរិក។ កម្មករជាច្រើនត្រូវទៅធ្វើការក្នុងរោងចក្រម៉ៅការបន្តដែលគ្មានការត្រួតពិនិត្យ និងអនុវត្តច្បាប់ត្រឹមត្រូវ ហើយបង់ប្រាក់ឈ្នួលទាប និងមានលក្ខខណ្ឌការងារមិនសមរម្យ។ កម្មកមួយចំនួនអះអាងថា ពួកគេពុំអាចស្វែងរកបានការងារធ្វើនៅក្រៅពីរោងចក្រម៉ៅការបន្តបានទេ ដោយសារពួកគេស្ថិតក្នុងបញ្ជីខ្មៅរបស់ក្រុមហ៊ុនRamatex។

# ០៣

# សេចក្ដីសន្និដ្ឋាន

ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនម៉ាកសម្លៀកបំពាក់ល្បីៗរបស់ពិភពលោកបានទម្លាក់ថ្លៃចំណាយនៃការងើបឡើងវិញពីជំងឺកូវីដ១៩ មកលើបណ្ដាប្រទេសអ្នកផ្គត់ផ្គង់ទាំងស្រុង ជាហេតុធ្វើឱ្យមានផលប៉ះពាល់យ៉ាងច្រើនដល់កម្មករនៅខ្សែសង្វាក់ផ្គត់ផ្គង់។ ប្រជាជនកម្ពុជា ពឹងផ្អែកលើការងារនៅក្នុងឧស្សាហកម្មកាត់ដេរអស់ពេលជាយូរមកហើយ ប៉ុន្តែនៅពេលប្រាក់ឈ្នួលធ្លាក់ចុះ និងថ្លៃចំណាយក្នុងការរស់នៅកើនឡើងជាគំហុក កម្មករកាត់ដេរនៅទូទាំងប្រទេសកម្ពុជា ជួបប្រទះបញ្ហាផ្នែកហិរញ្ញវត្ថុកាន់តែខ្លាំងឡើង ព្រមទាំងធ្វើឱ្យបញ្ហាវិបត្តិបំណុលរបស់គ្រួសារកាន់តែមានច្រើន។ សម្រាប់កម្មករជាច្រើននាក់ ស្ថានភាពរបស់ពួកគេគឺកាន់តែដុនដាប។

កម្មករកាត់ដេរទូទាំងពិភពលោក បានទាមទារឱ្យមានកំណែទម្រង់ក្នុងឧស្សាហកម្ម ជាយូរមកហើយ ដោយសារតែការកេងប្រវ័ញ្ចផលប្រយោជន៍កម្មករ។ ក្នុងពេលការរាតត្បាតនៃជំងឺកូវីដ១៩ បានធ្វើឱ្យការអំពាវនាវរបស់កម្មករកាន់តែលំបាកថែមទៀត។ បីឆ្នាំក្រោយការរាតត្បាតនៃជំងឺកូវីដ១៩ អនាគតកម្មករកាត់ដេរកម្ពុជា គឺមើលទៅមិនអំណោយផលសោះសម្រាប់ពួកគេ ស្របពេលដែលក្រុមហ៊ុនម៉ាករកប្រាក់បានរាប់ពាន់លានដុល្លារអាមេរិកពីកម្លាំងញើសឈាមរបស់កម្មករ និងហាក់មានចេតនាមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួនសាជាថ្មីម្ដងទៀត។

---

[i] Only “Instant Noodle” Unions Survive: Union Busting in Cambodia’s Garment and Tourism Sectors | HRW; Failure to Pay Terminal Benefits at Violet Apparel (Cambodia) Co., Ltd. | Worker Rights Consortium

[ii] សម្រាប់ព័ត៏មានបន្ថែមសូមមើល Nike Steals

## អង្គការអាក់សិនអេតកម្ពុជា

ផ្ទះលេខ ៣៣ ផ្លូវលេខ ៧១ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
លេខទំនាក់ទំនង៖ ០២៣ ២១១ ៤៦២
អ៊ីម៉ែល៖ e-mail.cambodia@actionaid.org

**ស្កេន** QR code **ដើម្បីទាញយករបាយការណ៍**